របាយការណ៍ប្រចាំខែឧសភា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប

## I.ស្ថានភាពរបស់មន្ទីរ

### ១.ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ

បច្ចុប្បន្នមន្ទីរមានបុគ្គលិកក្របខណ្ឌសរុបចំនួន ៧៨ នាក់ ស្ត្រី ១២ នាក់ គ្រប់គ្រងដោយប្រធាន ០១ រូប ទទួលបន្ទុកក្តាប់រួម និងអនុប្រធាន ០៦ រូប ក្នុងនោះមានស្ត្រី ០១ រូប មន្ត្រីអណ្តែត ០១ រូប មន្ត្រីកិច្ចសន្យា ០១ រូប ស្រី ។

- ការិយាល័យទាំង ១០ មាន បុគ្គលិកសរុប ៦០ នាក់ ស្ត្រី ១០ នាក់
- ការិយាល័យអភិវឌ្ឍន៍ជនបទក្រុង និងស្រុកមានបុគ្គលិកសរុបចំនួន ១១ រូប ក្នុងនោះស្ត្រី ចំនួន ០១ រូប
- បានទទួលខិតចូលពីស្ថាប័ន មន្ទីរ ក្រសួង និង អន្តរក្រសួងពាក់ព័ន្ធចំនួន ៦៩ លិខិត ក្នុងនោះលិខិតអញ្ជើញ ៦១ លិខិត
- បានបញ្ជូលលិខិតចេញទៅអង្គភាពមន្ទីរ / ស្ថាប័ន ថ្នាក់ដឹកនាំខេត្ត ក្រសួង អន្តរក្រសួងពាក់ព័ន្ធ សរុបចំនួន ៥៤ លិខិត

### ២.ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

- រត់ការឯកសារ និងបើកបៀវត្សប្រចាំខែឧសភា ឆ្នាំ ២០១៥
- រៀបចំធ្វើរបាយការណ៍ចំណាយថវិការដ្ឋប្រចាំខែឧសភា ឆ្នាំ ២០១៥
- ចូលរួមវគ្គបណ្តុះបណ្តាល ជំនាញលទ្ធកម្មសាធារណៈនៅសាលាខេត្ត
- ធ្វើឯកសារទូទាត់ និងបើកប្រាក់សោហ៊ុយបេសកកម្ម
- ធ្វើឯកសារទូទាត់ រជ្ជទេយ្យបុរេប្រទានជុំទី១ លើកទី១

### ៣.អធិការកិច្ច-សវនៈកម្ម÷ (គ្មានសកម្មភាព)

### ៤.ការិយាល័យ ផែនការ-ស្ថិតិ

- បូកសរុបរបាយការណ៍ប្រចាំ ខែឧសភា ឆ្នាំ ២០១៥
- ចូលរួមសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលស្រុកក្រឡាញ់ ឆ្នាំ២០១៥ - ២០១៧ ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ នៅសាលាស្រុកក្រឡាញ់
- ចូលរួមសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលស្រុកបន្ទាយស្រី ឆ្នាំ២០១៥ - ២០១៧ ថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៥ នៅសាលាស្រុកបន្ទាយស្រី

### ៥.កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ

- ចូលរួមវេទិកាសាធារណៈដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅស្រុកពួកខេត្តសៀមរាប
- សិក្ខាសាលាផ្សព្វផ្សាយ ច្បាប់សវណកម្ម និងស្តង់ដាសវណកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប

- ចូលរួមជុំរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៦ នៅសាលប្រជុំមន្ទីរអប់រំយុវជន និងកីឡាខេត្តសៀមរាប
- ចូលរួមវេទិកាសាធារណៈដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយនិង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅស្រុកអង្គរធំ
- ចូលរួម សិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលថ្នាក់ស្រុក (២០១៥ -២០១៧) នៅស្រុកក្រឡាញ់
- ចូលរួមពិគ្រោះយោបល់លើគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងរបស់ក្រុមហ៊ុន MENG XIN HONG FA (CAMBODIA) REDOURCES IND. នៅស្រុកជីក្រែង ខេត្តសៀមរាប បន្ទប់ប្រជុំលេខ ២ សាលាខេត្ត
- ចូលរួមបុណ្យចម្រើនព្រះជន្មាយុប្រគេនព្រះសុមង្គលសិលាចារ្យ ព្រះមេគុណខេត្តសៀមរាប និង ប្រកាសតែងតាំងមន្ត្រីសង្ឃខេត្ត ស្រុកចំនួន ០២ អង្គ នៅវត្តព្រះឥន្ទកោសីយ៍ ហៅវត្តលើ ខេត្តសៀមរាប
- សិក្ខាសាលាផ្សព្វផ្សាយការធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រជុំទី ៩ ឆ្នាំ ២០១៥ នៅសាលធំសាលាខេត្តសៀមរាប
- សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបី ឆ្នាំរំកិលស្រុកឆ្នាំ ២០១៥-២០១៧ សាលាស្រុកប្រាសាទបាគង
- សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ឆ្នាំ ២០១៥ នៅសាលប្រជុំសាលាស្រុកស្រីស្នំ
- ចូលរួមកិច្ចប្រជុំពិភាក្សាលើប្លង់ស្ថាបត្យកម្ម ដើម្បីកែសម្រួលទៅតាមតម្រូវការរបស់មន្ទីរ នីមួយៗ សាលប្រជុំលេខ ២ សាលាខេត្តសៀមរាប
- ចូលរួមសិក្ខាសាលាពិគ្រោះយោបលន្លុះបញ្ចាំង ស្តីពីគម្រោងអាហាររូបត្ថម្ភដែលរៀបចំ ដោយអង្គការភ្លែនអន្តរជាតិ នៅរាជធានីភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ជំនាញលទ្ធកម្មសាធារណៈ រយះពេល ៦ ថ្ងៃ នៅសាលប្រជុំ លេខ ៤ ខេត្តសៀមរាប
- ចូលរួមកិច្ចប្រជុំ និងចុះអនុស្សរណៈយោគបល់គ្នារវាងសាលាខេត្ត និង អង្គការស្នាក់នៅ ស្ម័គ្រចិត្តជួយបង្រៀន (HVTO) នៅបន្ទប់ប្រជុំលេខ ២ សាលាខេត្តសៀមរាប
- ចូលរួមកិច្ចប្រជុំណែនាំដើម្បីតម្រង់ទិសពីសកម្មភាពប្រមូលផ្តុំបញ្ហាមនុស្សធម៌ និងការកាត់ បន្ថយគ្រោះមហន្តរាយឆ្នាំ ២០១៥ នៅបន្ទប់ប្រជុំលេខ ១ សាលាខេត្តសៀមរាប
- ចូលរួមសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក នៅសាលាស្រុកបន្ទាយស្រី
- ចូលរួមពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី ១២ ទិវាពលកម្មអន្តជាតិ ០២ ឧសភា នៅភូមិវប្បធម៌ខេត្តសៀមរាប
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ១២ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី ០២ នៅបន្ទប់ប្រជុំលេខ ០១ សាលាខេត្តសៀមរាប

- ចូលរួមពិធី បដិសណ្ឋាកិច្ចនិងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភា នៃសាធារណៈរដ្ឋកូរ៉េ និងលោកជំទាវ នៅអគារ VIP នៃកាសយានដ្ឋានអន្តរជាតិសៀមរាប
- ចូលរួមប្រជុំគណៈកម្មការនាយកហិរញ្ញប្បទានសុខាភិបាល នៅអគារភ្នែក នៃមន្ទីរពេទ្យបង្អែកខេត្តសៀមរាប
- ចូលរួម សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង នៅសាលប្រជុំសាលាក្រុងសៀមរាប
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ទឹកស្អាតអនាម័យនៅស្រុកសូទ្រនិគម ឃុំសំ រោង រយះពេល ០២ ថ្ងៃ
- ចូលរួមប្រជុំពិភាក្សានិង ផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ ឆ្នាំ ២០១៤ នៅសាលប្រជុំ លេខ ០១ សាលាខេត្តសៀមរាប
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលការងារវាយតម្លៃភាពងាយរងគ្រោះ នៅសណ្ឋាគារ ស៊ីធីរីវ័រ ក្រុងសៀមរាប
- ចូលរួមសម្តែងការគួរសមជាមួយក្រុមហ៊ុន Mineber ដើម្បីធ្វើបទបង្ហាញអំពីគម្រោងនៃការ អភិវឌ្ឍន៍ នៅសាលប្រជុំ លេខ ១ សាលាខេត្តសៀមរាប
- ចូលរួមទិវាជីវះចម្រុះអន្តរជាតិ ឆ្នាំ ២០១៥ នៅសណ្ឋាគារបុរីអង្គរខេត្តសៀមរាប
- ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលសហគមន៍ដឹកនាំអនាម័យ (CLTS) នៅខេត្តពោធិសាត់ រយះពេល ០៤ ថ្ងៃ
- សិក្ខាសាលាផ្សព្វផ្សាយផែនការសកម្មភាពស្តីពី ការទប់ស្កាត់អំពើហឹង្សាលើស្ត្រី ២០១៤ - ២០១៨ នៅសណ្ឋាគារសោមាទេវីក្រុងសៀមរាប
- ចូលរួមធ្វើបទបង្ហាញលើប្រធានបទ សុខភាព និង អនាម័យនៅសហគមន៍ នៅស្នាក់ការសាខាកាកបាទក្រហមកម្ពុជាខេត្តសៀមរាប
- សិក្ខាសាលាផ្សព្វផ្សាយលទ្ធិផលនៃការស្រាវជ្រាវអាហារូបត្ថម្ភសហគមន៍នៅសាលប្រជុំអគារ ភ្នែកនៃមន្ទីរពេទ្យខេត្តសៀមរាប
- ចូលរួមបទបង្ហាញអំពីយុទ្ធសាស្ត្ររបស់មន្ទីរក្នុងសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ អាហារូបត្ថម្ភថ្នាក់សហគមន៍នៅមន្ទីរពេទ្យខេត្តសៀមរាប

## II. សកម្មភាពតាមវិស័យ

### ១.ការងារផ្លូវជនបទ

#### ១.១. ថវិកាក្រសួងអភិវឌ្ឍន៍ ÷

- លើកគម្រោងជួសជុលបន្ទាន់បាន ០២ ខ្សែ ប្រវែង ៤,៩ គ.ម
- ចុះស្រង់ទិន្នន័យផ្លូវបានចំនួន ៣០ ខ្សែ ប្រវែង ៧០,៣៧ គ.ម

#### ១.២. គម្រោងកែលម្អផ្លូវជនបទ (RRIP)

- ផ្លូវពីខ្នាស់-ចាន់សរ ស្រុកសូទ្រនិគម ប្រវែង ១៧ គ.ម

- ផ្លូវពីស្រុកព្នក-ស្រុកអង្គរជុំ ប្រវែង ២៩,៥ គ.ម

- ចុះពិនិត្យស្ថានភាពផ្លូវដែលបានសាងសង់រួចរបស់គម្រោងកែលម្អផ្លូវជនបទ (RRIP/ADB) ចំនួនមួយខ្សែ ស្ថិតនៅស្រុកអង្គរធំ- អង្គរជុំ និង ស្រុកវ៉ារិន

**១.៣.គម្រោកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ (RIP)** (គ្មានសកម្មភាព)

**១.៤.គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ ដំហាន ២ (EFAP II)**

- ◻ **គម្រោងសំណង់ស៊ីវិល (CVW)**
  - ផ្លូវគ្រួសក្រហម ពីឈូក-ចំបក់សរ ឃុំត្រីញ័រ ប្រវែង **៥ គ.ម** បានបញ្ចប់
  - ផ្លូវគ្រួសក្រហម ពីគោគដូង-ស្វាយឃុំត្រីញ័រ ប្រវែង **១,២៥ គ.ម** អនុវត្តបាន ៨០%
  - ផ្លូវគ្រួសក្រហម ពីថ្នាស-ធិបតី ឃុំត្រីញ័រ ប្រវែង **២.០៥ គ.ម** អនុវត្តបាន ៨០%
  - ផ្លូវគ្រួសក្រហម ភូមិកំភេម ឃុំកែវពិណ ប្រវែង **១ គ.ម** អនុវត្តបាន ៨០%
  - ផ្លូវគ្រួសក្រហម ភូមិស្វាយ ឃុំខ្នាត ប្រវែង **១,៥៩ គ.ម** អនុវត្តបាន ៨០%
  - ផ្លូវគ្រួសក្រហម ពីបង្កោង-ត្នោត សង្កាត់អំពិល ប្រវែង **២ គ.ម** អនុវត្តបាន ៨០%
  - ផ្លូវគ្រួសក្រហម ភូមិត្រពាំងរុន សង្កាត់អំពិល ប្រវែង **២,១ គ.ម** អនុវត្តបាន ៨០%
  - ផ្លូវគ្រួសក្រហម ភូមិរលួសលិច ឃុំរលួស ប្រវែង **១ គ.ម** អនុវត្តបាន ៨០%
  - ផ្លូវគ្រួសក្រហម ភូមិបំពេញរាជ -ស្វាយ-តាប្រុក ប្រវែង **៤ គ.ម** អនុវត្តបាន ៨០%
- ◻ **គម្រោងសាច់ប្រាក់ពលកម្ម (CFW)**
  - ជួសជុលផ្លូវដីសរ ភូមិតាប្រុក ឃុំលាងដៃ ប្រវែង ១ ០០០ ម
  - ជួសជុលផ្លូវដីសរ ភូមិត្រពាំងស្វាយ ឃុំលាងដៃ ប្រវែង ១ ៥៥៥ ម
  - ជួសជុលផ្លូវដីសរ ភូមិដូនឪ ឃុំលាងដៃ ប្រវែង ១ ៣០២ ម
  - ជួសជុលផ្លូវដីសរ ភូមិត្រីញ័រ ឃុំត្រីញ័រ ប្រវែង ១ ៣២១ ម
  - ជួសជុលផ្លូវដីសរ ភូមិចំបក់សរ ឃុំត្រីញ័រ ប្រវែង ៧០០ ម
  - ជួសជួលផ្លូវដីសរ ភូមិគោគចាន់ សង្កាត់អំពិល ប្រវែង ១ ១៦៨ ម
  - សាងសង់លូជ្រុង ០២ កន្លែង ប្រវែង ១២ ម

## ២. ការងារផ្គត់ផ្គង់ទឹក

**២.១.ថវិកាក្រសួងអភិវឌ្ឍន៍÷**

- ចុះស្រង់ទិន្នន័យអណ្តូងបានចំនួន ៤៥ អណ្តូង នៅភូមិគោគដូងថ្មី ខ្នារ គោគញ៉ោ និងភូមិគោគដូងចាស់ ឃុំគោគដូង ស្រុកអង្គរជុំ

**២.២.គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទជំហានទី ២** (គ្មានសកម្មភាព)

**២.៣.កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានរបស់អង្គការយូនីសេហ្វ**

- រៀបចំផែនការ ថវិកាសម្រាប់ខែ មិថុនា ឆ្នាំ ២០១៥

## ៣. ការងារថែទាំសុខភាព

៣.១. ថវិកាក្រសួងអភិវឌ្ឍន៍ ÷

- រៀបចំផែនការសកម្មភាព ចុះស្រង់ទិន្នន័យបង្គន់អនាម័យ សម្រាប់ខែឧសភា
- ចុះប្រមូលទិន្នន័យបង្គន់អនាម័យ នៅឃុំគោគដូង និងឃុំនគរភាស ស្រុកអង្គរជុំ
- រៀបចំឯកសារទូទាត់របាយការណ៍សកម្មភាពចុះស្រង់ទិន្នន័យបង្គន់អនាម័យ ខែមេសា ឆ្នាំ ២០១៥
- រៀបចំឯកសារសម្រាប់សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការកសាងផែនការសកម្ម ភាពជាតិសម្រាប់ខេត្ត លើការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

៣.២. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទជំហានទី ២ (គ្មានសកម្មភាព)

៣.៣. កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានរបស់អង្គការយូនីសេហ្វ

**៤. ការងារបណ្តុះបណ្តាល ÷**

| ទីកន្លែង | វគ្គបណ្តុះបណ្តាល | សិក្ខាសាលា | ទស្សនកិច្ចសិក្សា | សរុប | ស្រី |
|---|---|---|---|---|---|
| ក្រៅប្រទេស | 0 | 0 | 0 | 0 | 0 |
| ក្នុងប្រទេស | ៣ | ៩ | 0 | ១៩ | ២ |
| រៀបចំដោយមន្ទីរអ.ជ.ប | 0 | 0 | 0 | 0 | 0 |
| សរុប | ៣ | ៩ | 0 | ១៩ | ២ |

**៥. ការងារអភិវឌ្ឍន៍សហគមន៍÷**

- ចុះតាមដាន និងធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅឃុំរោងគោ និងក្រូចគរស្រុកក្រឡាញ់ ឃុំសង្វើយ ស្រុកជីក្រែង។

**៦. ការងារសេដ្ឋកិច្ច÷**

គម្រោងឥណទានគាំទ្រសុខភាពសហគមន៍ អនុវត្តន៍ក្នុងតំបន់គោលដៅចំនួន **៩ ភូមិ ៧ឃុំ** ៣ស្រុក សមាជិកខ្ចីទុន **៣៦៩ នាក់ ស្រី ៣១៩ នាក់ (៨១ ក្រុម)** ប្រើប្រាស់ទៅលើមុខរបរសំខាន់ៗ ៣ គឺ÷ កសិកម្ម ជំនួញតូចតាច និងសិប្បកម្ម។

| | | | |
|---|---|---|---|
| ទុនដើមឆ្នាំ | **២៥២ ៥00 000 ៛** | សងផ្តាច់ | **៧00 000 ៛** |
| ទុនកំពុងចរាចរ | **២៦៥ ៧៣0 000 ៛** | សងរំលោះក្នុងខែ | **២ ៩00 000 ៛** |
| ប្រាក់ខ្ចីក្នុងខែ | **៧ ៨៦0 000 ៛** | | |

**៧. ការងារយេនឌ័រ ÷**

- ចូលរួមកិច្ចប្រជុំលើកទី ១០ អណត្តិទី ២ ប្រចាំខែ មេសា ឆ្នាំ ២០១៥ របស់ គណៈកម្មាធិការពិគ្រោះយោបលកិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) នៅសាលប្រជុំលេខ ២ សាលាខេត្តសៀមរាប ។

**III.សន្និដ្ឋាន**

លទ្ធផលការងារដែលសម្រេចបានខាងលើនេះ គឺពិតជាបានមកដោយសារការចង្អុលបង្ហាញពីរថ្នាក់ដឹកនាំក្រសួងនិងការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំមន្ទីរ និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលបានយកចិត្តទុកដាក់

សហការជាមួយអាជ្ញាធរមូលដ្ឋាន និងទទួលខុសត្រូវខ្ពស់ក្នុងការបំពេញការងារ រហូតទទួលបានលទ្ធផលជោគជ័យ។ តែទោះជាយ៉ាងណាក្តីលទ្ធផលការងារទាំងនេះនៅពុំទាន់បានឆ្លើយតបទាំងស្រុងនូវផែនការដែលបានគ្រោងទុក ដែលទាំងនេះទៀមទាឲ្យមានការជ្រោមជ្រែងបន្ថែមទាំងសម្ភារ និងថវិកាដើម្បីបំពេញការងារឲ្យបានជោគជ័យតាមផែនការ ដែលបានគ្រោងទុក៕

ប្រធានមន្ទីរ